

# ថ្ងៃដែលក្រុមបន្លែទៅសាលារៀន

Let's Read
The Asia Foundation



នាវេលាព្រឹកមួយដូចសព្វដង រាជ បានដើរទៅសាលារៀនដោយទឹកមុខសប្បាយរីករាយ។ គេចូលចិត្តរៀនណាស់ហើយតែងតែទន្ទឹងរង់ចាំឱ្យដល់ថ្ងៃទៅសាលារៀន។ ស្រាប់តែពេលនោះ រាជ បានឃើញរបស់ម៉្យាងដែលមានរូបរាងចម្លែកនៅពីមុខគេ របស់នោះកំពុងស្ពាយកាតាបដើរទៅសាលារៀន។



នៅពេលដែល រាជ ដើរទៅជិត គេក៏ឆ្ងល់ថាតើនោះជាបន្លែ ដែលគេតែងតែឃើញនៅក្នុងផ្សារមែនឬទេ? រាជ ញីភ្នែកម្តង ហើយម្តងទៀតហាក់បីដូចជាមិនជឿទាល់តែសោះ។



បន្លែទាំងនោះមើលទៅពិតជាស្រស់និងមានសុខភាពល្អ
ណាស់។ ពួកវានាំគ្នាដើរឆ្ពោះទៅសាលាដូចជាកូនទាហាន ម្នាក់
នៅពីក្រោយម្នាក់ទៀត។





រាជ ដើរកាន់តែលឿនទៅៗ។ គេពិតជាចង់ដឹងពីមិត្តភក្តិថ្មីខ្លាំងណាស់ ហើយក៏ចង់មើលពួកគេឱ្យកាន់តែជិត។




មិនយូរប៉ុន្មាន រាជ ក៏បានឃើញរូបរាងរបស់ពួកវាច្បាស់។ គេសម្លឹងមើលដោយទឹកមុខភ្ញាក់ផ្អើល។



ដូចអ្វីដែលគេបានទាយពិតមែន ទាំងនោះគឺជាបន្លែមានដូចជា ៖ ដំឡូងបារាំង ដំឡូងជ្វា និងប្រភេទនៃពូជបន្លែជាមើមផ្សេងៗ ទៀតដែលគេបានឃើញនៅតាមផ្សារ។



ពិតជាពួកឯងមែនឬ? សំណួរនេះបានចេញពីមាត់ រាជ មុនពេលដែលគេបានដឹងច្បាស់។ ប៉ុន្តែពួកបន្លែមិនបានឆ្លើយតបវិញទេ។ ពួកវាបានងាកមើលគ្នាទៅវិញទៅមកហើយញញឹម។



បន្តិចក្រោយមក រាជ បានងាកក្រោយដោយចង់ដឹងថា តើបន្លែទាំងនោះនៅជុំវិញនោះទៀតឬទេ? ជាថ្មីម្ដងទៀត រាជ ភ្ញាក់ផ្អើលដោយឃើញក្រុមបន្លែស្លឹកបៃតងមកចូលរួមជាមួយនឹងក្រុមបន្លែមើម ស្ពាយកាតាប ដើរទៅសាលារៀន។



ឥឡូវនេះ រាជ បានចូលរួមជាមួយក្បួនបន្លែ គេសប្បាយចិត្ត
ណាស់។ មិនដែលមានអ្នកណាដើរទៅសាលារៀនជាមួយក្បួន
បន្លែដូចគេនោះទេ។



បន្តិចម្តងៗ ក្បួនបានទៅដល់សាលារៀន។ សិស្សទាំងអស់បានចេញក្រៅបន្ទប់រៀនមកមើលក្បួនដង្ហែដ៏ចម្លែកនេះ។ សិស្សទាំងអស់ភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ពួកគេបើក ភ្នែក និងមាត់ធំៗ។



អ្នកគ្រូរបស់ រាជ ចេញមកស្វាគមន៍ពួកគេ។ គាត់និយាយថា "ក្មេងល្អ!" ហើយទះខ្នង រាជ តិចៗ។ រាជ មានអារម្មណ៍ថា សប្បាយរីករាយខ្លាំងណាស់ហើយតបថា "អរគុណអ្នកគ្រូ!" សិស្សដទៃទៀតបានទះដៃនិងអបអរសាទរ រាជ។ អ្នកគ្រូបាន ដើរចេញ ចំណែកអ្នកផ្សេងទៀតបន្តទះខ្នងរបស់ រាជ ប៉ុន្តែរាង ខ្លាំងបន្តិចហើយ។



រាជ បើកភ្នែកឡើង ម្តាយរបស់គេបានអង្រួនគេឱ្យភ្ញាក់។ គាត់និយាយថា ”ភ្ញាក់ឡើង រាជ កូននឹងទៅសាលារៀនយឺតឥឡូវហើយ។” រាជ បានភ្ញាក់ដឹងខ្លួន ហើយនិយាយម្នាក់ឯង ”ខ្ញុំយល់សប្តិទេតើ!” ”យល់សប្តិអ្វីក៏ចម្លែកម្ល៉េះ!” រាជ ក្រោកពីគ្រែទាំងញញឹម។ រាជ ត្រូវតែប្រញាប់ប្រញាល់ប្រសិនបើគេចង់ទៅរៀនឲ្យទាន់ពេល។



Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Day the Vegetables Came to School*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang and Chou Chinith